# អំណោយនៃមិត្តភាព

ដោយ លូស៊ី ស្ទីវើនសុន
ទស្សនាវដ្ដីសាសនាចក្រ
( ផ្អែកទៅលើដំណើររឿងពិត )

*នេះគឺជារឿងរ៉ាវដែលបានកើតឡើងនៅប្រទេសអង់គ្លេស បន្ទាប់ពីសង្គ្រាមលោកលើកទីII ភ្លាម ។*

ហីមិន មូស្នឹ មានការភ័យខ្លាចពេលគាត់ដើរចូលទៅក្នុងរោងជំនុំ ។ គាត់ និងមិត្តភក្ដិរបស់គាត់ទើបមកពីជំរុំនៅក្នុងឯកសណ្ឋានរបស់ពួកគេនៅឡើយ ដោយមានប៉ាក់អក្សរ « P.O.W. » នៅលើអាវ ។ គ្រប់គ្នាបានដឹងថាអក្សរនោះតំណាងឲ្យ « អ្នកទោសសង្គ្រាម » ។ តើសមាជិកនៅក្នុងសាខាគិតយ៉ាងណាដែរ ? តើពួកគេឃើញគាត់ថាជាសត្រូវរបស់ពួកគេដែរទេ ?

សាលាប្រជុំនៅជិតទីក្រុងលីដស៍ ប្រទេសអង់គ្លេស ។ ប៉ុន្តែ ហីមិនមិនមែនមកពីប្រទេសអង់គ្លេសទេ ។ គាត់មកពីប្រទេសអាល្លឺម៉ង់ ។ បន្ទាប់ពីត្រូវបានបង្ខិតបង្ខំឲ្យប្រយុទ្ធក្នុងសង្គ្រាម លោកលើកទី II មក ហីមិនត្រូវបានចាប់ជាឈ្លើយសឹកដោយទាហ៊ានអង់គ្លេស ហើយបញ្ជូនទៅដាក់គុកក្នុងជំរំសម្រាប់សាសន៍អង់គ្លេស ។ វាជាលើកដំបូងសម្រាប់គាត់នៅព្រះវិហារបន្ទាប់មិនបានចូលរួមអស់រយៈពេលយ៉ាងយូរ ។

ហីមិន បានដកដង្ហើមធំ នៅពេលគាត់អង្គុយចុះលើកៅអី ? គាត់អាចមើលឃើញប្រធានសាខា ចច ខាំ អង្គុយនៅខាងមុខ ។ ប្រធាន ខាំ គឺជាមិត្តរបស់ហីមិន ។ ការឃើញស្នាមញញឹមរបស់គាត់ធ្វើឲ្យហីមិនមានអារម្មណ៍ប្រសើរឡើងបន្តិច ។

ពីរបីខែមុន ប្រធាន ខាំ បានទៅសួរសុខទុក្ខ ហីមិន នៅក្នុងជំរុំបន្ទាប់ពីបានទទួលដំណឹងថាគាត់គឺជាសមាជិកនៃសាសនាចក្រតែម្នាក់គត់នៅទីនោះ ។ ដំបូង ហីមិនមានការព្រួយបារម្ភណ៍បន្តិចបន្តួច ។ តើប្រធាន ខាំ នឹងស្អប់គាត់ដែរទេ ? ប្រទេសរបស់ពួកគេពិតជាបានច្បាំងគ្នានៅក្នុងសង្គ្រាម ។

ប៉ុន្តែនៅពេលដែលប្រធានខាំ និងហីមិនបានជួបគ្នា ពួកគេបានញញឹម និងចាប់ដៃគ្នា ។ បន្ទាប់មកពួកគេបានអធិស្ឋានជាមួយគ្នា ។ ពួកគេបានច្រៀងចម្រៀង និងនិយាយគ្នាអំពីដំណឹងល្អ ។ ពួកគេក៏បានទទួលទានសាក្រាម៉ង់ជាមួយគ្នាផងដែរ ។



ហីមិន បាននិយាយថា « ខ្ញុំស្រឡាញ់បងប្រុស » ពេលដែលប្រធានខាំចាកចេញ ។ គាត់បានឃើញប្រធានខាំស្រក់ទឹកភ្នែក នៅពេលគាត់លើកដៃលា ។

បន្ទាប់មកប្រធាន ខាំ បានទៅសួរសុខទុក្ខគាត់ជារៀងរាល់ថ្ងៃ សៅរ៍ ។ ក្នុងអំឡុងពេលនៃសប្ដាហ៍ ហីមិន បានរស់នៅតាមដំណឹងល្អឲ្យបានល្អបំផុត ។ គាត់បានចែកចាយទីបន្ទាល់របស់គាត់ជាមួយអ្នកទោសដទៃទៀត នៅពេលពួកគេធ្វើការនៅទីវាល ។ គាត់បានឆ្លើយនឹងសំណួរពួកគេ អំឡុងពេលគេឆ្លាក់ឈើ បន្ទាប់ពីធ្វើការយ៉ាងយូរពេញមួយថ្ងៃ ។ ពេលខ្លះគាត់បានអធិស្ឋានជាមួយពួកគេ ។

មានយប់មួយអ្នកទោសម្នាក់បានសួរថា « អេ ហីមិន » ។ « តើខ្ញុំអាចចូលរួមជាមួយលោក និងលោក ខាំ ថ្ងៃសៅរ៍នេះបានទេ ? »

ហីមិន បានមើលតាមបន្ទះឈើដែលគាត់ឆ្លាក់ ។ គាត់ញញឹម ។ « ប្រាកដជាបាន ! »

អ្នកទោសម្នាក់ទៀតក៏បានសួរថា « ខ្ញុំអាចចូលរួមដែរបានទេ ? »

ហីមិន និងប្រធាន ខាំ រំភើបចិត្តខ្លាំងណាស់ក្នុងការបង្រៀនបន្ថែមដល់អ្នកទោសទាំងនោះ ។ មិនយូរប៉ុន្មានអ្នកខ្លះថែមទាំងចង់ទទួលបុណ្យជ្រមុជទឹកទៀតផង !

ហើយឥឡូវនេះពេលដែលហីមិន ក្រឡេកមើលជុំវិញក្នុងរោងជំនុំនៅកន្លែងដែលក្រុមគ្រួសារកំពុងរង់ចាំឲ្យព្រះវិហារចាប់ផ្ដើម គាត់មានអារម្មណ៍សុខសាន្ត ។ ពីដំបូងសមាជិកខ្លះមានចិត្តភ័យញញើត ពេលនៅជិតហីមិន ។ ប៉ុន្តែមិនយូរប៉ុន្មានពួកគេបានទុកចិត្តគាត់ ។ អ្នកទោសដទៃទៀតដែលចង់រៀនអំពីដំណឹងល្អ បានទទួលការអនុញ្ញាតឲ្យចេញពីជំរុំទៅព្រះវិហារជាមួយ ហីមិន នៅថ្ងៃអាទិត្យក្រោយ ។ ក្រោយមក ហីមិន ថែមទាំងត្រូវបានហៅឲ្យធ្វើជាប្រធានថ្នាក់សាលាថ្ងៃអាទិត្យនៅក្នុងសាខាទៀតផង ។

ពេលវេលាកន្លងទៅ ហើយជិតដល់ថ្ងៃបុណ្យគ្រីស្ទម៉ាស់ ។ ហីមិន ចង់ធ្វើអ្វីមួយដើម្បីអរគុណសមាជិកដែលមានចិត្តល្អចំពោះគាត់ ។ ក្រោយមក គាត់មានគំនិតមួយ ! ជិតដល់ពេលជប់លៀងពិធីបុណ្យគ្រីស្ទម៉ាស់សាខាហើយ ។ ហីមិន បានប្រមូលដុំឈើ ហើយចាប់ផ្ដើមឆ្លាក់ ។ គាត់បានឆ្លាក់ឈើដែលមានរាងជាកូនទន្សាយ ដំរី យន្ដហោះ រថភ្លើង និងរូបសេះម្ដងមួយៗ ។

នៅទីបំផុត ថ្ងៃជប់លៀងបានមកដល់ ។ គ្រប់គ្នាបានបរិភោគអាហារ និងច្រៀងចម្រៀងគ្រីស្ទម៉ាស់រួមគ្នា ។ ហីមិន និង មិត្តរបស់គាត់មកពីជំរំបានច្រៀងបទគ្រីស្ទម៉ាស់ជាភាសាអាល្លឺម៉ង់ ។

បន្ទាប់មកហីមិនបានទាញកាបូបដ៏ធំចេញមក ។ នៅក្នុងនោះមានរបស់លេងពីឈើចំនួន ៤០ ដុំ ! ហីមិន បានឲ្យកុមារក្នុងអង្គការបឋមសិក្សាម្នាក់មួយៗ ។ វាគឺជាពិធីបុណ្យគ្រីស្ទម៉ាស់ដែលពួកគេមិនដែលភ្លេចឡើយ ។●



បន្ទាប់ពីនៅក្នុងជំរំរយៈពេលបីឆ្នាំមក ហីមិន បានត្រឡប់ទៅជួបជុំគ្រួសាររបស់គាត់នៅប្រទេសអាល្លឺម៉ង់វិញ ។ ប៉ុន្មានឆ្នាំក្រោយមក ហីមិន បានទៅលេងរោងជំនុំ ដែលគាត់ធ្លាប់បានចូលរួម កាលជាអ្នកទោសសង្គ្រាម ។ ក្មេងៗដែលធំឡើងហើយនោះបានប្រាប់គាត់ថា ពួកគេនៅតែមានរូបចម្លាក់តុក្កតាដែលគាត់បានឲ្យពួកគេកាលនៅពីក្មេង ។

